

# សិក្ខាសាលាស្តីពី
# ការរៀបចំផែនការអភិវឌ្ឍប្រញ្ញាញកាបូនតិចតាម
# បែបបរិមាណ និងជាប្រព័ន្ធសម្រាប់កម្ពុជា

## ការអភិវឌ្ឍទេសចរណ៍ និងផែនការគ្រប់គ្រងបរិស្ថាន

### ថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០១៣
### សណ្ឋាគារហ៊ីម៉ាវ៉ារី ភ្នំពេញ


រៀបចំដោយ: ប៊ូ ចន្ទ សិរី

អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍.MOT

Email:bouserey@yahoo.com

H.P:0979777789

# មាតិកា

១-សេចក្តីផ្តើម

២-ផែនការអភិវឌ្ឍសេវាកម្មសម្បទាទេសចរណ៍

៣- ផែនការ និងគោលដៅអភិវឌ្ឍទេសចរណ៍៤- ផែនការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាព

៥-ផែនការអភិវឌ្ឍ និងការគ្រប់គ្រងបរិស្ថាន

៦-ជម្រុញដល់ការប្រើប្រាស់ផលិតផលទេសចរណ៍បៃតង

៧-ដំណើរការរៀបចំផែនការទេសចរណ៍បរិស្ថាន

៨-សន្និដ្ឋាន

# ១ សេចក្តីផ្តើម

- ទេសចរណ៍កម្ពុជា ជាទេសចរណ៍ "វប្បធម៌ និងធម្មជាតិ"
- ទេសចរណ៍ បង្កើនចំណូលរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបច្រើនជាង១២% បង្កើតមុខរបរ និងឱកាសការងារ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។
- វិស័យទេសចរណ៍ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាព ទាំង ១០ សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។
- វិស័យទេសចរណ៍ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា កំណត់ជា "មាសបៃតង"
- ការអភិវឌ្ឍន៍ទេសចរណ៍ប្រកបដោយចិរភាព រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងជួយទប់ទល់ការប្រែប្រួលអាកាសធាតុ។

# ២- ផែនការអភិវឌ្ឍសេវាកម្មសម្បទាទេសចរណ៍

CAMBODIA Kingdom of Wonder

a/ ទេសចរណ៍កម្ពុជា ចំនួនសណ្ឋាគារ និងកន្លែងស្នាក់នៅ

| សណ្ឋាគារ | បន្ទប់ | ផ្ទះសំណាក់ | បន្ទប់ |
|---|---|---|---|
| ៤៤០ | ២៤៣៩៣ | ១០៨៧ | ១៥៣២១ |

b/ មានទីភ្នាក់ងារទេសចរណ៍ និងការីទេសចរណ៍៤៤០

c/ មានក្រុមហ៊ុនអាកាសចរជាតិ និងអន្តរជាតិ២៤

d/ មានភោជនីយដ្ឋានកំរិតស្តង់ដារជាតិ៩៣៤

e/ មានកន្លែង massages ជាង ១១១,

f/ មាន 21 sporting clubs; និង ២៩ 29 Souvenir shops and casino ២៩

g/ ឆ្នាំ២០១២:មានទេសចរអន្តជាតិ ៣,៦លាន និងទេសចរជាតិប្រមាណ៧លាននាក់

h/ ប្រាក់ចំណូលទេចរណ៍សរុបប្រមាណ២ពាន់លានដុល្លា

# ៣-ផែនការ និងគោលដៅអភិវឌ្ឍទេសចរណ៍

បានយកចិត្តទុកដាក់ដោយផ្សាភ្ជាប់ទៅលើ៖

- ការអភិវឌ្ឍន៍ផលិតផលទេសចរណ៍
- ការសិក្សាទីផ្សារ និងការផ្សព្វផ្សាយ
- ការតភ្ជាប់ និងការសម្រួលធ្វើដំណើរដឹកជញ្ជូនទេសចរណ៍
- ប្រព័ន្ធសុវត្ថិភាពទេសចរណ៍ និងការគ្រប់គ្រងផលប៉ះពាល់
- ប្រព័ន្ធ ច្បាប់ និងយន្តការគ្រប់គ្រង
- ការអភិវឌ្ឍធនធានមនុស្ស

# ៤ - ផែនការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាព



# ៤- ផែនការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាព (បន្ត)

បានកំពុងរៀបចំផែនការផែនការយុទ្ធសាស្រ្តតាមផ្នែកនីមួយៗដូចជា៖

- ផែនការទេសចរណ៍ តំបន់ឆ្នេរ
- ភូមិភាគព្រៃសាន
- តំបន់ជុំវិញបឹងទន្លេសាប
- ផែនការអភិវឌ្ឍទេសចរណ៍ តាមរាជធានី-ខេត្ត
- ផែនការ និងគោលនយោបាយអភិវឌ្ឍអេកូទេសចរណ៍
- ច្បាប់ស្តីពីអេកូទេសចរណ៍ ទេសចរណ៍សហគមន៍
- គោលការណ៍ណែនាំស្តីពីការរៀបចំសហគមន៍ទេសចរណ៍ ប្រកាសរួមស្តីពីការ គ្រប់គ្រងទេសចរណ៍ សហគមន៍ និងអេកូទេសចរណ៍។

# ៤- ផែនការអភិវឌ្ឍតំបន់ទេសចរណ៍អាទិភាព (បន្ត)

ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រវិស័យ ទេសចរណ៍មានដូចជាៈ

- ព្រលានយន្តហោះខ្នាតអន្តរជាតិធំ
- កសាងកំពង់ផែទេសចរណ៍បន្ថែមទៀតនៅតាមតំបន់ឆ្នេរ
- ព្រលាន ឬវាលយន្តហោះនៅ តាមខេត្តសំខាន់មួយចំនួន ដូចជាខេត្តបាត់ដំបង ខេត្តព្រះវិហារ ខេត្តរតនគិរី ខេត្តកោះកុង។ល។
- គម្រោងអភិវឌ្ឍន៍ទេសចរណ៍មេគង្គ ផ្តោតលើការកសាងផ្លូវទៅកាន់ជើងឯក គម្រោងចម្រោះទឹកកខ្វក់នៅខេត្តសៀមរាប ការកសាងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍១៦នៅខេត្តក្រុងចំនួន១៤ និងគម្រោង *លើកកម្ពស់ទីផ្សារលក់ ផលិតផលរបស់ជនក្រីក្រនៅខេត្តកំពង់ធំ។*

# ៥- ផែនការអភិវឌ្ឍ និងការគ្រប់គ្រងបរិស្ថាន

- ដើម្បីជាការគាំទ្រ និងធានាឲ្យកិច្ចអភិវឌ្ឍទេសចរណ៍ កម្ពុជាប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ក្រសួងបានសហការជាមួយ មន្ទីរ ស្ថាប័នអាជ្ញាធរ និងអង្គការដែលមានការពាក់ព័ន្ធ បង្កើតសហគមន៍ទេសចរណ៍បានចំនួន ៥៦សហគមន៍ នៅទូទាំងប្រទេស ។
- សហគមន៍ទេសចរណ៍ មានតួនាទីក្នុងការរួមចំណែកអភិវឌ្ឍន៍ទេសចរណ៍ ការការពារ ថែរក្សាបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និងទប់ស្កាត់ការធ្វើចំណាកស្រុក។

# ៥- ផែនការអភិវឌ្ឍ និងការគ្រប់គ្រងបរិស្ថាន (បន្ត)

ធ្វើកិច្ចសហប្រតិបត្តិការអាស៊ានដោយបានអនុម័តលើ:

- ស្តង់ដារសណ្ឋាគារបៃតងអាស៊ាន (ASEAN Green Hotel)
- ស្តង់ដារផ្ទះស្នាក់អាស៊ាន (ASEAN Home Stay)
- ស្តង់ដារស្ប៉ាអាស៊ាន (ASEAN Spa) និង
- ពិសេស ដោយឡែក ស្តង់ដារទីក្រុងទេសចរណ៍ស្អាតអាស៊ាន (ASEAN Clean Tourist City) និង
- ស្តង់ដារទេសចរណ៍ផ្អែកលើសហគមន៍អាស៊ាន (ASEAN CBT) ដែលអាស៊ានបាន ប្រគល់ជូនកម្ពុជាទទួលដឹកនាំ។
- កិច្ចសហការដើម្បីអភិវឌ្ឍទេសចរណ៍បៃតងក្នុងនោះផ្តោតលើ:

# ៥- ផែនការអភិវឌ្ឍ និងការគ្រប់គ្រងបរិស្ថាន(បន្ត)




ការគ្រប់គ្រងរួមគ្នាដើម្បីធ្វើការអភិរក្សធនធានធម្មជាតិ និងការប្រើប្រាស់ដោយភាពឆ្លាតវៃដើម្បីទទួលបាន:

- ប្រាក់ចំណូលសហគមន៍
- បង្កើតនូវការងារសំបូរបែប
- ចំណូលពន្ធ
- ការអភិរក្សបរិស្ថាន
- ការអភិរក្សដីធ្លី

# គោលបំណងយុទ្ធសាស្ត្រ(បន្ត)

**ការផានាក្នុងការការពារតំបន់មួយចំនួនដូចជា៖**

១-តំបន់អេកូទេសចរណ៍ និងទេសចរណ៍ធម្មជាតិ ឧទ្យានជាតិ ជម្រកសត្វ តំបន់ទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង តំបន់ដីសើម ។

២-ការយកចិត្តទុកដាក់ដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនៅតំបន់អភិរក្ស។

៣-បង្កើតនូវកម្មវិធីយល់ដឹងនិងផ្តល់បទពិសោធន៍ដល់សហគមន៍។

# ៦-ជម្រុញដល់ការប្រើប្រាស់ផលិតផលទេសចរណ៍បៃតង

រួមមាន: បទពិសោធន៍ប្រជាសហគមន៍ ធនធានជីវៈចម្រុះ វប្បធម៌ផ្សេងៗគ្នា សម្បទាទេសចរណ៍ខ្នាតតូច សំណង់អាគារទាំងឡាយ ដែលមានការយកចិត្តទុក ដាក់ លើផ្នែកបរិស្ថាន សេវាកម្មស្នាក់នៅ (lodging, homestay; inns…)

# ៧-ដំណើរការរៀបចំផែនការទេសចរណ៍បរិស្ថាន (ទេសចរណ៍បៃតង-Green Tourism)

- ការជួបប្រជុំជាមួយថ្នាក់ដឹកនាំ MOTនិងកូរ៉េ GGGI; CHU
- ការផ្លាស់ប្តូរដំណើរទស្សនះកិច្ច មន្ត្រីMOTនិងភាគីកូរ៉េ
- បានរៀបចំពង្រាង MOU-MOT & CHU ស្តីពីការអភិវឌ្ឍវិទ្យាស្ថានទេសចរជាតិបៃតង។
- បានបង្កើតក្រុមការងារទេសចរបៃតង MOT
- បានពង្រាងបញ្ចប់របាយការណ៍យុទ្ធសាស្រ្តជាតិទេសចរបៃតងជាមួយ CHU។
- បានធ្វើលទ្ធភាពសិក្សាស្តីពីគម្រោងសាងសង់វិទ្យាស្ថាន ជាតិបៃតង និងកន្លែងកំសាន្តអេកូទេសចរណ៍ & សិក្សាពីលទ្ធភាពថវិការក្នុងការប្រើប្រាស់។
- សិក្សាពីលទ្ធភាពរៀបចំកម្មវិធីសិក្សាជំនាញទេសចរ ណ៍ បៃតង។

# ៧-ដំណើរការរៀបចំផែនការទេសចរណ៍បរិស្ថាន (ទេសចរណ៍បៃតង-Green Tourism) មន្ត

បានយកចិត្តទុកដាក់ដោយផ្សព្វផ្សាយទៅលើ៖

- ការអភិវឌ្ឍន៍អេកូទេសចរណ៍
- ការប្រកួតប្រជែងទីក្រុងស្អាត
- យុទ្ធនាការដាំដើមឈើ
- ទស្សនទានស្អាត និងបៃតង
- ការគ្រប់គ្រងកាកសំណល់
- សម្ព័ទ្ធទេសចរណ៍បៃតង
- ស្តង់ដារសណ្ឋាគារបៃតង
- ការគ្រប់គ្រងតំបន់ឆ្នេរ។ល។

# ៨-សន្និដ្ឋាន

ការអភិវឌ្ឍទេសចរណ៍និងគ្រប់គ្រងបរិស្ថានមានន័យថារួមគ្នា៖
- ទទួលខុសត្រូវដើម្បីធ្វើអោយមាននិរន្តរភាពទេសចរណ៍
- អភិរក្សបរិស្ថាន និងប្រើប្រាស់ធនធានដោយភាពឆ្លាតវៃ
- យកចិត្តទុកដាក់ដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនិងមធ្យម នៅតាមតំបន់អភិរក្ស
- លើកកម្ពស់គុណភាព និងការអភិវឌ្ឍបៃតង
- បង្កើននូវកម្មវិធីយល់ដឹង និងផ្តល់បទពិសោធន៍ ដល់សហគមន៍ និងគ្រប់ភាគីពាក់ព័ន្ធ។

# សូមអរគុណចំពោះការយកចិត្ត ទុកដាក់ស្តាប់